ការកាត់បន្ថយការបំពុល និង ការរក្សាលំហូរបរិស្ថានក្នុងតំបន់ សមុទ្រអាស៊ីខាងកើតតាមរយៈ

ការអនុវត្តការគ្រប់គ្រង អាចទន្លេតាមវិធានចម្រុះ

នៅក្នុងប្រទេសជាសមាជិកអាស៊ាន

តើអ្វីជាគម្រោងការគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះ (IRBM)?

ទន្លេមានតួនាទីសំខាន់ក្នុងការទ្រទ្រង់ជីវិត គាំទ្រសហគមន៍ និងជំរុញសដ្ឋកិច្ច។ គម្រោងការគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះ(IRBM) មានគោលបំណងការពារប្រព័ន្ធទឹកសំខាន់ៗ ក្នុងចំណោមប្រទេសអាស៊ានចំនួន ៦។ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងអាងទន្លេ យើងអាចកាត់បន្ថយការបំពុល ធានាបាននូវលំហូរទឹក និងត្រៀមខ្លួនទប់ទល់នឹងបញ្ហាការប្រែប្រួលអាកាសធាតុ។

ទីតាំងអនុវត្តគម្រោង **IRBM**

This graphic is not drawn to scale and is provided for illustration purposes only.

គោលបំណងរបស់យើង

បង្កើតប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងអាងទន្លេ ដែលរក្សាសុខមាលភាពទន្លេ កាត់បន្ថយការបំពុល និង ធានាឱ្យមានលំហូរទឹកស្អាតគ្រប់គ្រាន់សម្រាប់មនុស្សជាតិ ធម្មជាតិ និងជីវភាពរស់នៅ។

បេសកកម្មរបស់យើង

យើងកំពុងធ្វើការដើម្បីពង្រឹងអំពីរបៀបអភិបាលកិច្ច និងគ្រប់គ្រងទន្លេ ដោយ៖

កាត់បន្ថយការបំពុលចេញពីកសិដ្ឋាន រោងចក្រ និងសកម្មភាពលើដី

ការពារ និងអភិរក្សលំហូរទឹកសម្រាប់សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី

ជួយសហគមន៍ក្នុងការ បន្សាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈ ការធ្វើឱ្យប្រសើរឡើងនូវការរៀបចំផែនការ និងការអនុវត្ត

តើគម្រោង IRBM អនុវត្តដោយរបៀបណា?

យើងផ្តោតលើកិច្ចការស្នូលចំនួន ៤ ដើម្បីសម្រេចបាននូវគោលបំណង៖

ស្វែងយល់អំពីទន្លេរបស់យើង

ធ្វើការតាមដានយ៉ាងម៉ត់ចត់ដើម្បីស្វែងយល់ពីស្ថានភាពបច្ចុប្បន្នរបស់ទន្លេ និងបញ្ហាប្រឈមដែលជួបប្រទះ។

តើអ្វីជាលទ្ធផល?

របាយការណ៍ស្ថានភាពអាងទន្លេដែលកំណត់អំពីសកម្មភាព និងការសម្រេចចិត្ត ដើម្បីភាពប្រសើរឡើងនៃ ការគ្រប់គ្រង និងអភិបាលកិច្ច។

ពង្រឹងការគ្រប់គ្រងអាងទន្លេ

យើងកំពុងជាក់ចេញគោលនយោបាយ និងគម្រោងសាកល្បងដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងអភិបាលកិច្ចទន្លេ។

តើមានរួមបញ្ចូលអ្វីខ្លះ?

- គម្រោងសាកល្បង៖ ធ្វើតេស្តសាកល្បងការអនុវត្តដំណោះស្រាយសម្រាប់ការគ្រប់គ្រងឱ្យកាន់តែល្អប្រសើរ រួមមានការសិក្សាពីភាពអាចទៅរួច ការប្រឹក្សាជាសាធារណៈ និងផែនការថវិកា។
- ភាពល្អប្រសើរឡើងនៃគោលនយោបាយ និងឧបករណ៍៖ បង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាព ផ្អែកលើការអនុវត្តដែលល្អ ការធ្វើបច្ចុប្បន្នភាពច្បាប់ និងការពង្រឹងភាពជាដៃគូរ។

ការកសាងចំណេះដឹង និងជំនាញ

យើងផ្តល់ឱ្យសហគមន៍ អ្នកធ្វើការសម្រេចចិត្ត និងអ្នកជំនាញនូវចំណេះដឹង និងឧបករណ៍ដែលពួកគាត់ត្រូវការក្នុងការថែរក្សាទន្លេ។

អ្វីដែលត្រូវបានផ្តល់ឱ្យ?

- កម្មវិធីបណ្តុះបណ្តាលលើការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព
- ឧបករណ៍សម្រាប់តាមដានគុណភាពទឹក និងវឌ្ឍនភាព
- វេទិកាចែករំលែកចំណេះដឹង និងគំនិត
- ឱកាសក្នុងការផ្សារភ្ជាប់តាមរយៈវេទិកា កម្មវិធីផ្លាស់ប្តូរ និងបណ្តាញទំនាក់ទំនង។

ការវាស់វែងភាពជោគជ័យ

យើងតាមដានអំពីវឌ្ឍនភាព ដើម្បីធានាថាលទ្ធផលនៃគម្រោងផ្តល់នូវអត្ថន័យ និងចីរភាព។

តើធ្វើវាដោយរបៀបណា?

- ការពិនិត្យប្រចាំឆ្នាំ ដើម្បីវាយតម្លៃវឌ្ឍនភាព
- ការវាយតម្លៃឯករាជ្យនៅពាក់កណ្តាល និងចុងបញ្ចប់នៃគម្រោង
- ចងក្រងឯកសារអំពីការអនុវត្តល្អ និងបទពិសោធន៍ទទួលបានសម្រាប់ពង្រីក និងយកទៅអនុវត្តបន្ថែម។

ហេតុអ្វីបានជាវាជាបញ្ហា?

ទន្លេដែលមានគុណភាពល្អគឺជាមូលដ្ឋានគ្រឹះនៃការរីកចម្រើនរបស់សហគមន៍ ភាពធន់ប្រព័ន្ធអេកូឡូស៊ី និងចីរភាពសេដ្ឋកិច្ច។ តាមរយៈគម្រោង IRBM ប្រទេសសមាជិកអាស៊ានរួបរួមគ្នាក្នុងការការពារ ធនធានដ៏សំខាន់ទាំងនេះ ដើម្បីធានាបាននូវអនាគតល្អប្រសើរសម្រាប់មនុស្សជំនាន់ក្រោយ។

ព័ត៌មានគម្រោង

ជំនួយមូលនិធិរបស់
មូលនិធិបរិស្ថានសកល **(GEF):**

USD 8,479,123

កាលបរិច្ឆេទចាប់ផ្តើម៖ ខែមករា ឆ្នាំ២០២៣
កាលបរិច្ឆេទបញ្ចប់៖ ខែធ្នូ ឆ្នាំ២០២៧

ទីភ្នាក់ងារអនុវត្ត៖ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ **(UNDP)**
ទីភ្នាក់ងារប្រតិបត្តិ៖ ភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថានសម្រាប់ធនធានសមុទ្រអាស៊ីបូព៌**(PEMSEA)**

ដៃគូរអនុវត្តជាតិ

ក្រសួងបរិស្ថានកម្ពុជា
ក្រសួងបរិស្ថាន និងព្រៃឈើ ឥណ្ឌូនេស៊ី
ក្រសួងធនធានធម្មជាតិ និងបរិស្ថានឡាវ
ក្រសួងផ្ទៃថាមពល និងបំលែងទឹក ម៉ាឡេស៊ី
នាយកដ្ឋានបរិស្ថាន និងធនធានធម្មជាតិ ហ្វីលីពីន
ក្រសួងកសិកម្ម និងបរិស្ថាននៃប្រទេសវៀតណាម

ព័ត៌មានបន្ថែមអំពី
គម្រោង **IRBM!**

(+63) 2 892 92992

info@pemsea.org

PEMSEA Building, DENR Compound,
Visayas Avenue, Quezon City 1165,
Philippines

PEMSEA **pemsea** **pemsea.rf**

www.pemsea.org